ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 26-Mar-2015, 15:59
CMS/CFO: Sann Rada

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-កញ្ញា-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
Case File/Dossier N°. 002/19-09-2007-ECCC/SC

| | |
|---|---|
| **នៅចំពោះមុខ៖** | **ចៅក្រម គង់ ស្រ៊ីម ជាប្រធាន** |
| | **ចៅក្រម Chandra Nihal JAYASINGHE** |
| | **ចៅក្រម សោម សិរីវឌ្ឍ** |
| | **ចៅក្រម Agnieszka KLONOWIECKA-MILART** |
| | **ចៅក្រម ម៉ុង មុន្នីចរិយា** |
| | **ចៅក្រម Florence Ndepele MWACHANDE-MUMBA** |
| | **ចៅក្រម យ៉ា ណារិន** |
| **កាលបរិច្ឆេទ៖** | **ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥** |
| **ភាសា៖** | **ខ្មែរ/អង់គ្លេស** |
| **ចំណាត់ថ្នាក់ឯកសារ៖** | **សាធារណៈ ជាមួយឧបសម្ព័ន្ធសម្ងាត់បំផុត** |

---

# សេចក្តីណែនាំពាក់ព័ន្ធនឹងសាក្សីនានាដែលភាគីបានស្នើឡើងនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១

---

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**ជនជាប់ចោទ**

ខៀវ សំផន
នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE

**សហមេធាវីការពារក្តី ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ
Arthur VERCKEN

១. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុង ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួលបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១[1]។ នួន ជា ស្នើសុំថា អង្គជំនុំជម្រះតុលាការកំពូលគួរកោះហៅសាក្សីចំនួនប្រាំបួននាក់ នៅក្នុងកិច្ចដំណើរការនិតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១[2]។ អង្គជំនុំជម្រះសូមអនុម័តនូវសេចក្តីណែនាំនានាដូចខាងក្រោម ដែលភាគីនានាក្នុងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ត្រូវអនុវត្តតាម ពាក់ព័ន្ធនឹងសាក្សីនានាដែលភាគីបានស្នើឡើង។

២. សាក្សីមួយចំនួនក្នុងចំណោមសាក្សីដែល នួន ជា បានស្នើសុំ ត្រូវបានស្នើឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ ហេតុនេះអត្តសញ្ញាណរបស់សាក្សីទាំងនេះត្រូវបានផ្សព្វផ្សាយជាសាធារណៈរួចទៅហើយ[3]។ ហេតុនេះ ការអនុវត្តដែលត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូងរួមមាន សាក្សីទាំងអស់ត្រូវបានកំណត់ជារហស្សនាម ចាប់តាំងពីពេលដែលពួកគេត្រូវបានស្នើឡើងដោយភាគី រហូតដល់ពេលដែលពួកគេមកផ្តល់សក្ខីកម្ម ឬ សំណើសុំកោះហៅពួកគេត្រូវបានបដិសេធ ដោយមិនគិតដល់ថាតើ វិធានការការពារត្រូវបានចេញ ឬ

---

[1] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ F11 ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ឯកសារ F16 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ ("សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា")។ *[Corrigé 1] Mémoire d'appel de la Défense de M. KHIEU Samphân contre le jugement rendu dans le procès 002/01* ឯកសារ F17 ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ (សំណៅដែលបានកែប្រែត្រូវបានដាក់នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤)។

[2] សារណាលើបណ្តឹងសាទុក្ខរបស់ នួន ជា កថាខណ្ឌ ៧៣០(ក) និង (គ)។ សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2 ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៤ ("សំណើលើកទីមួយ") កថាខណ្ឌ ១៨(ខ)។ សំណើលើកទីបី សុំឱ្យពិចារណា និងទទួលយកភស្តុតាងបន្ថែម ទាក់ទងបណ្តឹងសាទុក្ខប្រឆាំងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/4 ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (សំណៅសម្ងាត់បំផុតត្រូវបានជូនដំណឹងមកភាគីនៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០១៤។ សំណៅកោសលុបសម្រាប់សាធារណៈត្រូវបានជូនដំណឹងនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤) ("សំណើលើកទីបី") កថាខណ្ឌ ៣៤(ខ)។

[3] *សូមមើល* សេចក្តីសម្រេចស្តាពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានស្តាប់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/ឯកសារ E312 ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។

មិនបានចេញនោះទេ[4]។ ចំណុចនេះគឺដើម្បីបញ្ចៀសនូវការលូកលាន់ដោយមិនចាំបាច់ទៅក្នុងជីវិតឯកជនរបស់សាក្សីដែលភាគីបានស្នើឡើង និងស្របទៅតាមការខិតខំប្រឹងប្រែងរក្សាសុចរិតភាពនៃភស្តុតាង។ សាក្សីផ្សេងទៀតដែលបានស្នើសុំ ត្រូវបានភាគីនានាក្នុងសំណុំរឿង ០០២ ស្គាល់អស់ហើយ ដោយសារមានការដាក់បង្ហាញកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយពីសំណុំរឿង ០០៤[5]។ ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតនីតិវិធីពិសេសមួយ ដើម្បីរក្សាភាពសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងបន្តក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលអនុញ្ញាតឱ្យមានការពិភាក្សាដេញដោលលើភស្តុតាងក្នុងអំឡុងសវនាការជាសាធារណៈ[6]។

៣. ពាក់ព័ន្ធនឹងសាក្សីនានាដែលភាគីបានស្នើឡើងពីសំណុំរឿង ០០៤ អង្គជំនុំជម្រះតុលាការកំពូលសង្កេតឃើញថា ការដាក់បង្ហាញត្រូវបានអនុញ្ញាតដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្រោមលក្ខខណ្ឌតឹងរ៉ឹង ក្នុងគោលបំណងរក្សាសុចរិតភាព និងភាពសម្ងាត់នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៤[7]។ ដោយសារ

---

[4] *សូមមើល ឧទាហរណ៍* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "របាយការណ៍សម្រាប់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើសុំឱ្យមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២" ឯកសារ E305/15 ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៤។

[5] *សូមមើល ឧទាហរណ៍* សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) ឯកសារ E319/5 ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ [កែប្រែលើកទី១] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងសេចក្តីបង្គាប់ស្តីពីការប្រើប្រាស់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤ ឯកសារ E319/7 ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤")។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវកំណត់ហេតុស្តាប់ចម្លើយសាក្សីពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងវគ្គទីមួយ នៃសវនាការក្នុងសំណុំរឿង ០០២/០២ ឯកសារ E319/8 ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥។ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យទទួលយកឯកសារដែលទាក់ទងនឹងសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) (សម្ងាត់) ឯកសារ E319/11 ចុះថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០១៥។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឯកសារ E319/12 ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៥។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ អនុលោមតាមសំណុំរឿង០០៤-D193/11 ឯកសារ E319/13 ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥។ ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នូវឯកសារមួយចំនួនពីសំណុំរឿង ០០៤ និងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ អនុលោមតាមសំណុំរឿង០០៤-D193/13 ឯកសារ E319/15 ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៥។ *សូមមើលផងដែរ* ព័ត៌មាន និងការបំភ្លឺអំពីដំណើរការនៃការដាក់បង្ហាញឯកសារក្នុងសំណុំរឿង ០០២/០២ [sic] ក្នុងបរិបទនៃកិច្ចស៊ើបសួរដែលកំពុងធ្វើនៃសំណុំរឿង ០០៣ និង ០០៤ ឯកសារ E319/14 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥។

[6] សេចក្តីសម្រេចលើសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤ កថាខណ្ឌ ១១ ដល់ ១៣ និង សេចក្តីសម្រេច។

[7] *សូមមើល ឧទាហរណ៍* ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង ០០៤ នៅក្នុងវគ្គទីមួយ នៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ (សម្ងាត់បំផុត) ឯកសារ E319.2 ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១៤

មានសំអាងហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ថា វាជាការសមរម្យដែលត្រូវអនុម័តយកនីតិវិធីពិសេសដែលត្រូវបានបង្កើតឡើងដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីនេះ និងដើម្បីណែនាំឲ្យភាគីត្រូវអនុវត្តតាមនីតិវិធីនេះ*ដូចគ្នា (mutatis mutandis)* នៅក្នុងក្របខណ្ឌនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនេះ។

៤. អង្គជំនុំជម្រះតុលាការកំពូលប្រកាន់យកវិធានការនានាទាក់ទិននឹងសាក្សីផ្សេងទៀតដែលភាគីបានស្នើឡើង ដែលអ្នកទាំងនោះមិនស្ថិតក្រោមការបង្គាប់ឲ្យមានវិធានការការពារដែលបានចេញអនុលោមតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទេ។ អង្គជំនុំជម្រះយល់ឃើញថា ទោះបីមានអង្គហេតុបែបនេះក៏ដោយ ក៏ការប្រើរហស្សនាមសម្រាប់សាក្សីដែលភាគីបានស្នើឡើងទាំងនេះ អាចត្រូវបានផ្តល់យុត្តិកម្ម ដើម្បីការពារឯកជនភាពរបស់សាម៉ីជន នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។ ទោះជាយ៉ាងណា ផលប្រយោជន៍ទាំងនេះអាចត្រូវតែមានតុល្យភាពទល់នឹងគោលការណ៍តម្លាភាព និងភាពជាសាធារណៈ នៃកិច្ចដំណើរការនីតិវិធីដែរ[8]។ ក្នុងករណីនេះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ទម្ងន់ដែលផ្តល់ឲ្យផលប្រយោជន៍នៃឯកជនភាពត្រូវបានកាត់បន្ថយ នៅពេលដែលសំណើសុំឲ្យកោះហៅសាក្សីត្រូវបានធ្វើឡើងម្តងហើយម្តងទៀតពីសំណើនានាពីមុន ដែលត្រូវបានដាក់នៅពេលសវនាការ ហើយអត្តសញ្ញាណរបស់សាក្សីត្រូវបានដាក់បង្ហាញ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីទាំងនេះ ឬនៅពេលសាក្សីដែលភាគីស្នើឡើងអាចត្រូវបានចាត់ទុកថាជាបុគ្គលសាធារណៈ។

៥. ពាក់ព័ន្ធនឹងចំណុចខាងលើ អង្គជំនុំជម្រះតុលាការកំពូលបានកំណត់រហស្សនាមតែចំពោះសាក្សីមួយក្នុងចំណោមសាក្សីដែលភាគីស្នើឡើងប៉ុណ្ណោះ ដូចមានរៀបរាប់ក្នុងតារាងឧបសម្ព័ន្ធ ក[9]។

## ផ្នែកសម្រេចសេចក្តី

៦. ដោយសារមានសំអាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូលសម្រេចៈ**

---

("ដីកាសម្រេចដាក់បង្ហាញលើកទី១") កថាខណ្ឌ ២៣ ដល់ ២៦។ ដីកាសម្រេចលើសំណើបន្ទាន់របស់សហព្រះរាជអាជ្ញា សុំដាក់បង្ហាញការស្តាប់ចម្លើយសាក្សីដែលទើបបញ្ចូលថ្មីៗទៅក្នុងសំណុំរឿង ០០៤ នៅក្នុងវគ្គទីមួយ នៃការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ (សម្ងាត់បំផុត) ឯកសារ E319/8.3 ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("ដីកាសម្រេចដាក់បង្ហាញលើកទី២") កថាខណ្ឌ ១៣ ដល់ ១៦។

[8] *សូមមើល* សេចក្តីណែនាំអនុវត្តស្តីពីការចាត់ថ្នាក់ឯកសារ និងការរៀបចំព័ត៌មានពាក់ព័ន្ធរឿងក្តី អវតក/០០៤/២០០៩/វិ.២ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ មាត្រា ១.២។

[9] ឧបសម្ព័ន្ធ កៈ បញ្ជីរហស្សនាមសម្រាប់សាក្សីនានាដែលភាគីបានស្នើឡើងនៅក្នុងបណ្តឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ឯកសារ F22.1 ភ្ជាប់មកជាមួយនឹងសេចក្តីសម្រេចនេះ។

**បន្ទាប់**ភាគីឲ្យអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

ក) ភាគី មេធាវី ឬ បុគ្គលផ្សេងទៀត មិនត្រូវបញ្ចេញអត្តសញ្ញាណ ដោយផ្ទាល់មាត់ក្ដី ឬតាមវិធីណាផ្សេងក្ដី នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ ដែលត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញនៅក្នុងដីកាសម្រេចឲ្យដាក់បង្ហាញ[10] ឬ នៅក្នុងការអនុញ្ញាតស្រដៀងគ្នានាពេលខាងមុខពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ដូចជាចម្លើយសាក្សី ឬ កំណត់ហេតុស្ដាប់ចម្លើយ ដែលមានប្រភពពីសំណុំរឿង ០០៣ ឬ ០០៤ ទេ។

ខ) ភាគី មេធាវី ឬ បុគ្គលផ្សេងទៀត មិនត្រូវបញ្ចេញអត្តសញ្ញាណ ឬដាក់បង្ហាញ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាម្នាក់ ដែលមិនត្រូវបានអនុញ្ញាតដោយដីកាសម្រេចឲ្យដាក់បង្ហាញ នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយខាងលើ នៅថ្ងៃនៃការស្ដាប់ចម្លើយ ឬ ដូចជាចម្លើយសាក្សី ឬ កំណត់ហេតុស្ដាប់ចម្លើយ ដែលមានប្រភពពីសំណុំរឿង ០០៣ ឬ ០០៤ តែផ្ទុយទៅវិញត្រូវបញ្ចេញអត្តសញ្ញាណនៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ ដែលមានលេខឯកសារត្រូវបានកំណត់ក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានការដាក់បង្ហាញឯកសារនោះក្នុងសំណុំរឿង ០០២ តែប៉ុណ្ណោះ។

គ) ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ភាគី មេធាវី ឬបុគ្គលផ្សេងទៀតដែលអាន ដកស្រង់ ឬ ប្រើប្រាស់កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយតាមវិធីផ្សេងទៀតដែលត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ នៅក្នុងដីកាសម្រេចឲ្យដាក់បង្ហាញ មិនត្រូវបញ្ចេញអត្តសញ្ញាណឈ្មោះបុគ្គលដែលបានផ្ដល់ចម្លើយក្នុងសំណុំរឿង ០០៣ ឬ ០០៤ នៅក្នុងកំណត់ហេតុជាសាធារណៈទេ។

ឃ) ភាគី មេធាវី ឬបុគ្គលផ្សេងទៀតដែលអាន ដកស្រង់ ឬ ប្រើប្រាស់កំណត់ហេតុជាលាយលក្ខណ៍

---

[10] ដីកាសម្រេចដាក់បង្ហាញលើកទី១។ ដីកាសម្រេចដាក់បង្ហាញលើកទី២។ ដីកាសម្រេចផ្នែកខ្លះលើសំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បង្ហាញឯកសារស្ដាប់ចម្លើយសំណុំរឿង ០០៤ ដែលពាក់ព័ន្ធនឹងសវនាការនៃសំណុំរឿង ០០២/០២ និងបណ្ដឹងសាទុក្ខនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E319/12.1.1 ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៥ ដូចដែលត្រូវបានកែប្រែដោយការកែប្រែដីកាសម្រេចដាក់បង្ហាញឯកសារ D193/4, D193/6 និង D193/8 (សម្ងាត់) ឯកសារ E319/12.1.2 ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥។ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំដាក់បង្ហាញឯកសារ D193/7 និង D193/9 សម្រាប់សំណុំរឿង ០០២ (សម្ងាត់បំផុត) ឯកសារ E319/13.1.1 ចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៥។ ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំដាក់បង្ហាញក្នុងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងសាក្សីម្នាក់ (សម្ងាត់បំផុត) ឯកសារ E319/15.1 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ (រួមគ្នាហៅថា "ដីកាសម្រេចដាក់បង្ហាញ")។

អក្សរនៃការស្តាប់ចម្លើយតាមវិធីផ្សេងទៀតដែលត្រូវបានអនុញ្ញាតឲ្យដាក់បង្ហាញ នៅក្នុងដីកាសម្រេចឲ្យដាក់បង្ហាញ ត្រូវបញ្ចេញអត្តសញ្ញាណឈ្មោះសាក្សីដែលផ្តល់ចម្លើយក្នុងសំណុំរឿង ០០៣ ឬ ០០៤ ត្រឹមតែរហស្សនាមដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២ ឬ ដោយអង្គជំនុំជម្រះតុលាការកំពូលសម្រាប់សំណុំរឿង ០០២/០១ តែប៉ុណ្ណោះ ឬ នឹងប្រើប្រាស់តែពាក្យពេចន៍ទូទៅប៉ុណ្ណោះ ដែលអាចបញ្ចៀសមិនឲ្យបញ្ចេញអត្តសញ្ញាណសាក្សី។ និង

ង) នៅពេលដែលសាក្សី ឬ ដើមបណ្តឹងរដ្ឋប្បវេណីដែលកំពុងផ្តល់សក្ខីកម្មត្រូវបានសួរដេញដោលនៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ពួកគេក្នុងសំណុំរឿង ០០៣ ឬ ០០៤ នោះ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយត្រូវតែបញ្ចេញអត្តសញ្ញាណត្រឹមតែ ចម្លើយដែលបុគ្គលនោះបានផ្តល់ដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតពីមុនតែប៉ុណ្ណោះ[11]។

**បង្គាប់**ភាគីឲ្យបញ្ចេញអត្តសញ្ញាណសាក្សីដែលបានស្នើឡើង ដោយប្រើរហស្សនាម នៅក្នុងសារណានានាទាំងអស់នាពេលខាងមុខ នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រីម**

[11] *សូមមើល* សេចក្តីសម្រេចលើសាក្សីក្នុងសំណុំរឿង ០០៣ និង ០០៤ សេចក្តីសម្រេច។